# ព័ត៌មានក្នុងពេលមានអាសន្ន

MCCSA
Multicultural Communities Council of South Australia

**ចូររៀបចំឲ្យមានស្រេចនូវពិលដែលមានថ្មឬដែលមានប្រដាប់វៃហើយនិងវិទ្យុ ក្រែងលោអស់ថ្មក្នុងគ្រាអាសន្ន ឬក៏ទូរសព្ទចល័តរបស់អ្នកមិនដំណើរការ។ ចូរធ្វើតេស្តថ្មជាប្រចាំ។**

ABC គឺជាអ្នកផ្សព្វផ្សាយជាផ្លូវការអំពីគ្រោះអាសន្ន - ស្ថានីយ៍វិទ្យុ ABC
នៅមូលដ្ឋានផ្សព្វផ្សាយដំណឹងឲ្យប្រយ័ត្នដែលពាក់ព័ន្ធនិងតំបន់របស់ពួកគេ

កម្មវិធី ABC Listen app អនុញ្ញាតិឲ្យអ្នកស្តាប់ការផ្សព្វផ្សាយអំពីស្ថានភាពគ្រោះអាសន្នពីស្ថានីយ៍វិទ្យុ ABC ណាក៏បានក្នុងប្រទេសអូស្ត្រាលី។ សូមទាញយកវានៅ https://www.abc.net.au

Emergency Plus ប្រើលក្ខណសម្បត្តិរបស់ GPS នៅក្នុងទូរសព្ទទំនើបដើម្បីជួយជនដែលហៅលេខសូន្យ៣ដង (000)ក្នុងការផ្តល់ព័ត៌មានអំពីទីតាំងដែលគេត្រូវការចាំបាច់សម្រាប់ចាត់ចែងសេវាសង្គ្រោះបន្ទាន់។
សូមទាញយកវានៅ www.emergencyplus.com.au

Addinsight
ពញ្ញាក់អ្នកអំពីភាពគ្រោះថ្នាក់ឬប្រាប់ឲ្យដឹងអំពីការយឺតយ៉ាវក្នុងបណ្តាញផ្លូវនៃក្រុងអាឌើឡែតតាមរយៈឧឃោសនសព្ទនៃទូរសព្ទរបស់អ្នក ឬបរិក្ខារមិនបាច់ប្រើដៃចុច ឬស្តេរ៉េអូឡាន។
សូមទាញយកវានៅ https://addinsight.com/

Alert SA បញ្ចាំងនៅក្នុងអេក្រង់នូវការពញ្ញាក់ឲ្យដឹងអំពីភ្លើងឆេះព្រៃ ការប្រាប់ឲ្យប្រយ័ត្ន ការផ្តល់ព័ត៌មានថ្មីៗ ចំណាត់ថ្នាក់នៃភាពដែលអាចមានភ្លើងឆេះព្រៃ និងការហាមបង្កាត់ភ្លើងទាំងស្រុង។
អ្នកប្រើអាចបង្កើតពហុតំបន់សម្រាប់តាមដានមើល ដោយកំណត់តំបន់ទាំងឡាយណាដែលខ្លួនមានចំណាប់អារម្មណ៍។
សូមទាញយកវានៅ https://alert.sa.gov.au/

BOM Weather – កម្មវិធីនេះអនុញ្ញាតិឲ្យអ្នកចូលមើលព័ត៌មានឧតុនិយមសម្រាប់តំបន់មូលដ្ឋានដែលធ្វើជារៀងរាល់ម៉ោង និង៧ថ្ងៃម្តង ព័ត៌មានរ៉ាដានិងព័ត៌មានឲ្យប្រយ័ត្ន – ទោះអ្នកនៅទីណាក៏ដោយ – ពីប្រភពនៃព័ត៌មានផ្លូវការអំពីជាតុអាកាសគឺការិយាល័យឧតុនិយម។
សូមទាញយកវានៅ www.bom.gov.au

**ចូររៀបចំឥឡូវនេះតែម្តង !**

សារនេះផ្តល់ជូនលោកអ្នកដោយ Multicultural Communities Council of South Australia ជាផ្នែកមួយនៃគំពេងកាត់បន្ថយហានិភ័យពីគ្រោះមហន្តរាយ ឧបត្ថមថវិកាដោយរដ្ឋាភិបាលសហព័ន្ធអូស្ត្រាលី និងរដ្ឋាភិបាលនៃរដ្ឋអូស្ត្រាលីខាងត្បូង។